01204857



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 18 / 07 / 2016
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

## <u>សាធារណៈ</u>

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ពុធ ទី ២៧ ខែ មករា ឆ្នាំ ២០១៦

## **សវនាការលើភ័ស្តុតាង - ថ្ងៃ ៣៦៤**

រៀបចំដោយ៖ **ជា ស៊ីវហ៊ង** និង Roger PHILLIPS

| <u>កំណត់ហេតុអ្នកចូលរួម</u> |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Claudia FENZ, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc Lavergne, ចៅក្រម យូ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ កញ្ញា ជា ស៊ីវហ៊ង, លោក Niccolo PONS , លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Vincent De Wilde d' ESTMAEL, កញ្ញា សុង ឆវ័ន្ត, លោក ស្រ៊ា រតនៈ |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD, លោក វ៉ែន |

| |
|---|
| ពៅ, លោក ឡោ ជុនធី, លោកស្រី ទី ស្រីនណា |
| ដើមបណ្ដឹង/សាក្សី៖ ព្រុំ សារ៉ាត (2-TCW-1009), លោកស្រី អ៊ុន យឿង (2-TCW-849) |
| មេធាវីប្រឹក្សា៖ មឿន សុវណ្ណ |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី ស្ល សុធាវី |
| ផ្សេងៗ៖ លោក ឡូញ ង៉ែត, លោក លឿង សូភ័ក្ត, លោក ឡាយ ណារ៉ា, លោកស្រី សំ មករា |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ | ចាប់ផ្ដើមម៉ោង៖ ០៩.០៣ | បញ្ចប់ម៉ោង៖ ១៦.០៥ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.១៤ | បញ្ចប់ម៉ោង៖ ១០.៣១ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៣៥ | បញ្ចប់ម៉ោង៖ ១៣.៣២ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៣៩ | បញ្ចប់ម៉ោង៖ ១៥.០១ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ម៉ោង និង ២៧ នាទី |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៣ | ០៩.០៥ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.០៥ | ០៩.០៦ |
| សេចក្ដីណែនាំរបស់អង្គជំនុំជម្រះទៅកាន់អ្នកបកប្រែ ក្នុងអំឡុងពេលសួរដេញដោលសាក្សី ព្រុំ សារ៉ាត (2-TCW-1009) | អង្គជំនុំជម្រះ | ០៩.០៦ | ០៩.០៧ |
| ការបន្តការតាំងសំណួរទៅកាន់សាក្សី ព្រុំ សារ៉ាត (2-TCW-1009) | សហព្រះរាជអាជ្ញា<br><br><br>អង្គជំនុំជម្រះ<br><br>មេធាវីការពារក្ដី ខៀវ សំផន | ០៩.០៧<br>០៩.៤៩<br>១០.៣១<br>១១.០៨<br>១៣.៣៥<br>១៥.០២ | ០៩.៤០<br>១០.១៤<br>១១.០៧<br>១១.៣៤<br>១៤.៤០<br>១៥.៤១ |

| | | | |
|---|---|---|---|
| ការជំទាស់ទៅនឹងចម្លើយសារភាព/ភ័ស្តុតាងដែលបានមកពីអំពើទារុណកម្ម | មេធាវីការពារក្តី ខៀវ សំផន អង្គជំនុំជម្រះ | ០៩.៤០ | ០៩.៤៩ |
| ការជូនដំណឹងរបស់អង្គជំនុំជម្រះទៅកាន់សាក្សី ព្រុំ សារ៉ាត អំពីអវត្តមានរបស់មេធាវីប្រឹក្សានៅក្នុងសវនាការពេលរសៀល | អង្គជំនុំជម្រះ | ១៣.៣៣ | ១៣.៣៥ |
| ការតាំងសំណួរទៅកាន់សាក្សី (2-TCW-849) | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា | ១៥.៤៤<br>១៥.៥៤ | ១៥.៥៤<br>១៦.០៥ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម សាលសវនាការ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**សេចក្តីណែនាំរបស់អង្គជំនុំជម្រះទៅកាន់ អ្នកបកប្រែក្នុងអំឡុងពេលសួរដេញដោល សាក្សី ព្រុំ សារ៉ាត (2-TCW-1009)**

អង្គជំនុំជម្រះបានណែនាំដល់អ្នកបកប្រែភាសាថា នៅពេលដែលភាគីប្រើប្រាស់ពាក្យថា “យួន” អ្នកបកប្រែត្រូវប្រើប្រាស់ពាក្យដូចគ្នា ហើយប្រសិនបើភាគីប្រើប្រាស់ពាក្យថា “វៀតណាម” នោះអ្នកបកប្រែត្រូវប្រាស់ពាក្យ វៀតណាម។

**ការបន្តការតាំងសំណួរទៅកាន់សាក្សី ព្រុំ សារ៉ាត (2-TCW-1009)**

សហព្រះរាជអាជ្ញា អង្គជំនុំជម្រះ មេធាវីការពារក្តី ខៀវ សំផន បានតាំងសំណួរទៅកាន់សាក្សី ព្រុំ សារ៉ាត (2-TCW-1009)។

**ការជំទាស់ទៅនឹងចម្លើយសារភាព/ភ័ស្តុតាងដែលបានមកពីអំពើទារុណកម្ម**

សហព្រះរាជអាជ្ញាបានស្នើសុំអាននូវខ្លឹមសារនៅក្នុងឯកសារដែលបានមកពីការចាក់ផ្សាយវិទ្យុភ្នំពេញ

ដែលមានចំណងជើងថា "ចម្លើយសារភាពរបស់ទាហានជើងទឹកវៀតណាមដែលត្រូវបានចាប់ខ្លួន"។ មេធាវីការពារក្តី ខៀវ សំផន បានជំទាស់ទៅនឹងការប្រើប្រាស់ខ្លឹមសារនៃការចាក់ផ្សាយនេះ ដោយហេតុថា វាមិនស្របច្បាប់ក្នុងការអានចម្លើយសារភាពនេះ។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខ្លួនមិនមានបំណងប្រើប្រាស់ខ្លឹមសារនៅក្នុងឯកសារនោះដើម្បីអះអាងពីភាពត្រឹមត្រូវនៃឯកសារនោះទេ។ មេធាវីការពារក្តី ខៀវ សំផន បានអះអាងថា អនុលោមតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល (ឯកសារ F26/11) ភាគីមិនត្រូវបានអនុញ្ញាតិឱ្យប្រើប្រាស់ខ្លឹមសារនៃចម្លើយសារភាពដែលបានមកពីបុគ្គលដែលត្រូវបានចាប់ខ្លួននោះទេ ទោះបីជាហេតុផលនៃការប្រើប្រាស់នោះជាអ្វីក៏ដោយ។ បន្ថែមពីលើនេះទៀត ខ្លឹមសារនៃអ្វីមួយដែលទទួល បានដោយសារអំពើទារុណកម្ម ឬ អាចទទួលបានដោយសារអំពើទារុណកម្ម ក្នុងករណីជាចម្លើយសារភាព គឺត្រូវបានហាមឃាត់ជាដាច់ខាត។ អង្គជំនុំជម្រះយល់ស្របតាមសេចក្តីជំទាស់នេះ ហើយសម្រេចថា សំណួរនេះមិនអនុញ្ញាតិឱ្យសួរទៅកាន់សាក្សីនោះទេ ដោយសារវាពាក់ព័ន្ធនឹងខ្លឹមសារនៃចម្លើយសារភាព។

<u>ការជូនដំណឹងរបស់អង្គជំនុំជម្រះទៅកាន់សាក្សី ព្រុំ សារ៉ាត អំពីអវត្តមានរបស់មេធាវីប្រឹក្សានៅក្នុងសវនាការពេលរសៀល</u>

សាក្សី ព្រុំ សារ៉ាត (2-TCW-1009) បានបញ្ជាក់ថាគាត់អាចផ្តល់សក្ខីកម្មបាន ដោយមិនមានជំនួយពីមេធាវីប្រឹក្សាក្នុងអំឡុងពេលសវនាការនាពេលរសៀល។

<u>ការតាំងសំណួរទៅកាន់សាក្សី (2-TCW-849)</u>

អង្គជំនុំជម្រះ និងសហព្រះរាជអាជ្ញា បានតាំងសំណួរទៅកាន់សាក្សី អ៊ុន យឿង (2-TCW-849)។

Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9113 | E305/13.23.400 | 00926341-00926437 00974154-00974260 | Statement of PRUM Sarat (DC-Cam) | P | 00926384, 00926385 00926425 00926431-00926432 | 00974206, 00974207 00974249 00974253-00974254 | / |
| E3/997 | D108/28.215 | 00020982-00020982 00233649-00233649 00623220- | Confidential Telephone Message on 20/03/78: to respect Brother 89 | P | 00020982 | 00233649 | 00623220 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 00623220 | about situation on the sea | | | | |
| E3/227 | 13.3 | 00019127-00019135 00183409-00183415 00290861-00290869 | [Corrected] The Permanent's Meeting of committee on 2-11-75 at 7 o'clock at night | P | 00019135 | 00183414 | 00290869 |
| E3/1143 | D366/7.1.338 | 00008510-00008534 00535793-00535818 00504099-00535818 | DK Military Meeting Minutes entitled "First General Staff Study Session." | P | / | / | / |
| E3/1249 | D29914 | 00224832-00224836, 00008892-00008899 00292680-00292690 | Swedish Collection Document 1978 | P | / | 00008894 | 00292685 |

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/847 | 18.22 | 00008459-00008470 00195322-00195338 00623199-00623216 | DK Military Report entitled "Second General Staff Study Session." | P | 00008465,00008466 | 00195330, 00195332 | 00623208, 00623211 |
| E3/9697 | D54/87 | 00985309-00985343 01055460-01055491 00998466-00998488 | Written Record of Interview of PRUM Sarat | C | 00985314-00985315, 00985323-00985324 00985332 00985333-00985334 | 01055465 01055473 01055481 01055482 | 00998469-00998470 00998475-00998476 00998481-00998482 |
| E3/9674 | D54/23 | 00955478-00955490 00977526-00977537 | Written Record of Interview of PAK Sok ប៉ា ក៏ | C | 00955478-00955479, 00955486, 00955487 | 00977526-00977527, 00977534, | 00976195-00976196, 00976203, 00976204 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 00976195-00976206 | ស៊ុខ Dated 18-10-2013 | | | 00977535, | |
| E188 | / | 00573327-00573773 00572517-00572797 00572190-00572516 | [Corrected 1] [Redacted] Judgment in Case 001 | P | / | / | / |
| E3/9698 | D114/19 | 01034016-01034028 01040432-01040444 | Written Record of Interview of Mak Chhoeun dated 22-10-2014 | C | 01034022-01034024 | 01040438-01040440 | / |
| E3/13 | / | 00052402-00052416 00940336-00940358 00334972-00334984 | Note of Secretary meeting, vice secretary, and regiment, about situation to defense the country and the measure to defense the country | P | 00052403-00052414 00052407-00052408 | 00940337 00940355 00940345-00940346 | 00334972-00334983 00334977-00334978 |
| E3/9699 | D54/98 | 00990382-00990405 01076839-01076868 01118077-01118097 | Written Record of Interview of HEANG Ret | C | 00990394 | 01076854 | 01118087 |

<u>**ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖**</u>

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៥)
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.០០ ព្រឹក នៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៦។ (១៦.០៣)

| <u>កាលវេលាសវនាការបន្ត</u> |
| --- |
| សវនាការនឹងបន្តទៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៦ ចាប់ផ្ដើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦

ក្រឡាបញ្ជី ក្រឡាបញ្ជី

ជា សុវណ្ណឫទ្ធិ Roger PHILLIPS